សមាគមធានារ៉ាប់រងកម្ពុជា
Insurance Association of Cambodia

# ខ្លឹមសារសង្ខេបនៃសិក្ខាសាលា ស្តីពី
# “ម៉ាឃីធីងសេវាធានារ៉ាប់រងប្រកបដោយភាពច្នៃប្រឌិត៖ ការធ្វើឲ្យលេចធ្លោនូវឈ្មោះ និងតម្លៃផលិតផលធានារ៉ាប់រង”









Cambodia Re Building, 2nd Floor, #17, St. 134, Sangkat Mittapheap, Khan 7 Makara, Phnom Penh, CAMBOIDA.
Tel: +855 92 778 111, Fax: +855 23 986 516, Email: info@iac.org.kh, Website: www.iac.org.kh.

នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ សមាគមធានារ៉ាប់រងកម្ពុជា បានរៀបចំសិក្ខាសាលា ស្តីពី “ម៉ាឃិធីងសេវាធានារ៉ាប់រងប្រកបដោយភាពច្នៃប្រឌិត៖ ការធ្វើឲ្យលេចធ្លោនូវឈ្មោះ និងតម្លៃផលិតផលធានារ៉ាប់រង” នៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រោមការចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ម៉ី វ៉ាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានវាគ្មិនជាតិ ចូលរួមចែករំលែក អំពីចំណេះដឹង និងបទពិសោធន៍ថ្មីៗ ក្នុងគោលបំណងការលើកកម្ពស់កម្រិតសមត្ថភាពជំនាញរបស់អ្នកផ្តល់សេវាធានារ៉ាប់រងវិជ្ជាជីវៈនៅកម្ពុជាទាំងអស់ ក្នុងការធ្វើម៉ាឃិធីងប្រកបដោយភាពច្នៃប្រឌិត។

ថ្លែងក្នុងពិធីបើកសិក្ខាសាលា ឯកឧត្តម **ម៉ី វ៉ាន់** បានគូសបញ្ជាក់ថា វិស័យធានារ៉ាប់រងត្រូវបានចាត់ទុកជាសសរស្តម្ភមួយនៃវិស័យ ហិរញ្ញវត្ថុ នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ ហើយដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការធ្វើបច្ចុប្បន្នភាព។ ក្រោមទិសដៅនៃយុទ្ធសាស្ត្រនេះ ក៏ដូចជាយុទ្ធសាស្ត្រដែលកំពុងធ្វើបច្ចុប្បន្នភាព កង្វះសមត្ថភាពនៃបុគ្គលិកវិជ្ជាជីវៈនៅតែត្រូវបានចាត់ទុកជាបញ្ហាប្រឈមមួយរបស់ឧស្សាហកម្មធានារ៉ាប់រងនៅកម្ពុជា។ ទោះយ៉ាងណាក៏ដោយ ការប្រើប្រាស់សេវាធានារ៉ាប់រងពីសំណាក់ប្រជាពលរដ្ឋនៅមានកម្រិតទាបខ្លាំងនៅឡើយ បើធៀបនឹងបណ្តាប្រទេសក្នុងតំបន់ ហើយចំណេះដឹងអំពីអត្ថប្រយោជន៍ធានារ៉ាប់រងរបស់ប្រជាពលរដ្ឋក៏នៅមានកម្រិតទាបនៅឡើយដែរ។ ក្នុងបរិបទនេះ ការធ្វើម៉ាឃិធីង និងការជំរុញការលក់ គឺជាសកម្មភាព ចាំបាច់ជំរុញដល់ការរីកធំធាត់នៃវិស័យធានារ៉ាប់រងនៅកម្ពុជា។

ឯកឧត្តមក៏បានបញ្ជាក់ផងដែរថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យធានារ៉ាប់រងមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ជាក់ស្តែងបុព្វលាភធានារ៉ាប់រងទូទៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយមានកំណើនជាមធ្យម២០%ក្នុងមួយឆ្នាំ ដែលបុព្វលាភដុលក្នុងឆ្នាំ២០១៥ បានឡើងដល់ចំនួន ៦១,៥ លានដុល្លារអាមេរិក។ ជាងនេះទៅទៀត ធានារ៉ាប់រងអាយុជីវិតដែលទើបមានកំណើតមិនដល់៤ឆ្នាំផងនោះ បុព្វលាភក៏មានការកើនឡើង យ៉ាងខ្លាំងផងដែរ ជាក់ស្តែងបុព្វលាភធានារ៉ាប់រងអាយុជីវិតក្នុងឆ្នាំ២០១៥ សម្រេចបាន ២២ លានដុល្លារ អាមេរិក កើនឡើងជិត ៣ដង ធៀបនឹងបុព្វលាភឆ្នាំ២០១៤ ដែលមានចំនួនតែ ៧,៦ លានដុល្លារអាមេរិក ប៉ុណ្ណោះ។ ចំណែកឯធានារ៉ាប់រងខ្នាតតូច ក៏បង្ហាញនូវភាពខ្លាំងរបស់ខ្លួនដែរ ដែលក្នុងនោះបុព្វលាភក្នុងឆ្នាំ២០១៥ ទទួលបានចំនួន ១,៨ លានដុល្លារ កើនឡើង ៤៧៧% ធៀបនឹងឆ្នាំ២០១៤។ នេះសបញ្ជាក់ឲ្យឃើញថា វិស័យធានារ៉ាប់រងក្នុងប្រទេស កម្ពុជា កាន់តែទទួលបានទំនុកចិត្តពីអតិថិជនកាន់តែច្រើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

លោក **ហ៊ុយ វ៉ាថារ៉ូ** ប្រធានសមាគមធានារ៉ាប់រងកម្ពុជា បានបញ្ជាក់ថា ទន្ទឹមនឹងការរីកចម្រើននៃទីផ្សារធានារ៉ាប់រងដ៏គួរឲ្យកត់សម្គាល់នេះ វិស័យធានារ៉ាប់រងនៅកម្ពុជា ក៏មានតម្រូវការលើធនធានមនុស្សកាន់តែច្រើន លើជំនាញផ្សេងៗនៅក្នុងខ្សែសង្វាក់ផលិតកម្មធានារ៉ាប់រង (insurance value chain) រួមទាំង ការធ្វើម៉ាឃិធីងផងដែរ។ ដូច្នេះ ការធ្វើម៉ាឃិធីង ក៏ត្រូវមានលក្ខណៈពិសេសដែលអាចទាក់ទាញអ្នកប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព ក្នុងបរិបទដែល ប្រជាពលរដ្ឋកម្ពុជានៅមានការយល់ដឹងទាបនៅឡើយ អំពីតម្រូវការសេវាធានារ៉ាប់រងនេះ។

ជាចុងបញ្ចប់ឯកឧត្តម **ម៉ី វ៉ាន់** ក្នុងនាមជាបញ្ញត្តិករ ឯកឧត្តមសូមលើកទឹកចិត្ត និងជំរុញគ្រប់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់យកចិត្តទុកដាក់បន្ថែមទៀតទៅលើការផ្តល់សេវាកម្ម ការអភិវឌ្ឍផលិតផលរបស់ខ្លួន ការបង្កើតយុទ្ធសាស្រ្តថ្មីៗដើម្បីធ្វើយ៉ាងណាទាក់ទាញអតិថិជន ក៏ដូចជាផ្តល់នូវទំនុកចិត្តទីផ្សារឲ្យកាន់តែច្រើនថែមទៀត។ ឯកឧត្តមសង្ឃឹមយ៉ាងមុតមាំថា ការខិតខំប្រឹងប្រែងរបស់សមាគមធានារ៉ាប់រងកម្ពុជា ក្នុងការរៀបចំឲ្យមានសិក្ខាសាលាថ្ងៃនេះ នឹងផ្តល់ឱកាសឲ្យអ្នកចូលរួម មិនត្រឹមតែទទួលបាននូវចំណេះដឹងថ្មីៗ និងមានយុទ្ធសាស្រ្ត ក្នុងការបង្កើនប្រាក់ចំណូលដល់ក្រុមហ៊ុនប៉ុណ្ណោះទេ ប៉ុន្តែវាជួយជំរុញការប្រើប្រាស់សេវាធានារ៉ាប់រងកាន់ តែច្រើនដែលផ្តល់ជូនប្រជាពលរដ្ឋ នូវសំណាញ់សុវត្ថិភាពសម្រាប់ការគ្រប់គ្រងហានិភ័យរបស់ខ្លួន។




រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៦

**សមាគមធានារ៉ាប់រងកម្ពុជា**


Cambodia Re Building, 2nd Floor, #17, St. 134, Sangkat Mittapheap, Khan 7 Makara, Phnom Penh, CAMBOIDA.
Tel: +855 92 778 111, Fax: +855 23 986 516, Email: info@iac.org.kh, Website: www.iac.org.kh.